អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន

## ព័ត៌មានស្តីអំពីការកំណត់កាលបរិច្ឆេទក្នុងសំណុំរឿង ០០២/០២

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានជូនដំណឹងដល់ភាគីទាំងអស់នៃសំណុំរឿង ០០២/០២ ថា ពុំមានសវនាការទេនៅក្នុងអំឡុងសប្តាហ៍ថ្ងៃទី ១៩-២២ ខែ តុលា ឆ្នាំ ២០១៥ ក្រោយពីឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ។

ការផ្អាកសវនាការនេះត្រូវបានធ្វើឡើងជាចាំបាច់ ដោយផ្អែកលើសំណើនានារបស់ភាគីសុំពេលវេលាបន្ថែមដើម្បីត្រៀមរៀបចំសម្រាប់សវនាការបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ ដែលត្រូវធ្វើឡើងនៅថ្ងៃទី ១៦-១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥។ ការផ្អាកសវនាការនេះត្រូវបានធ្វើឡើងជាចាំបាច់ផងដែរ ដើម្បីឲ្យអង្គជំនុំជម្រះរៀបចំបញ្ចប់សេចក្តីសម្រេចសំខាន់ៗមួយចំនួនទៅលើសំណើនានាដែលភាគីបានដាក់ជូនអង្គជំនុំជម្រះ ដោយអង្គជំនុំជម្រះយល់ឃើញថា គួរចេញសេចក្តីសម្រេចលើសំណើទាំងនោះ មុនពេលស្តាប់សក្ខីកម្មរបស់សាក្សីបន្ថែមទៀតនៅក្នុងសំណុំរឿងនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោក ឡាស អូលសិន
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរសព្ទលើតុ: +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.phektra@eccc.gov.kh